**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

## អត្ថបទសារព័ត៌មាន

# “សុខភាពស្ត្រីល្អ កម្ពុជារឹងមាំ” របស់ AIA Cambodia និងក្រសួងកិច្ចការនារី ចូលរួមចំណែកលើកកម្ពស់អ្នកចូលរួមចំនួន 900 លើការយល់ដឹងពាក់ព័ន្ធនឹងជំងឺមហារីក អាហារូបត្ថម្ភ និងផ្នែកហិរញ្ញវត្ថុ

កាលពីពេលថ្មីនេះ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក (“AIA Cambodia”) និងក្រសួងកិច្ចការនារី បានបញ្ចប់ឆ្នាំទី 1 លើគម្រោង **លើកកម្ពស់សុខភាព និងហិរញ្ញវត្ថុសម្រាប់ស្ត្រីកម្ពុជា** ដែលគម្រោងនេះមានរយៈពេល 5ឆ្នាំ ដោយបានផ្តល់វគ្គបណ្តុះបណ្តាលថ្នាក់មូលដ្ឋានដល់ស្ត្រីចំនួន 900 លើចំណេះដឹងពាក់ព័ន្ធនឹងជំងឺមហារីក អាហារូបត្ថម្ភ និងផ្នែកហិរញ្ញវត្ថុ។

ការសម្រេចបាននូវ គោលបំណងរបស់ AIA Cambodia ក្នុងការជួយប្រជាជនកម្ពុជាឱ្យមានសុខភាព និងជីវិតកាន់តែប្រសើររបស់ភាពជាដៃគូ ក្នុងការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រក្នុងវិស័យសុខាភិបាល ធ្វើឡើងតាមរយៈផ្សព្វផ្សាយព័ត៌មានអំពីជំងឺមហារីកមាត់ស្បូន និងជំងឺមហារីកសុដន់ អត្ថប្រយោជន៍នៃរបបអាហារត្រឹមត្រូវ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ដើម្បីប្រាកដថាស្ត្រី និងប្រជាជននៅទីតាំងគោលដៅរបស់គម្រោងទទួលបានចំណេះដឹង ក្រុមហ៊ុន និងក្រសួងបានរៀបចំវេទិកាផ្សព្វផ្សាយអប់រំទៅដល់សហគមន៍ផ្ទាល់ ក៏ដូចជាផ្គត់ផ្គង់សម្ភារៈអប់រំ និងសកម្មភាពនានាទាំងលើប្រព័ន្ធឌីជីថល និងជួបទំនាក់ទំនងផ្ទាល់។

គម្រោងរវាងរដ្ឋាភិបាល និងវិស័យឯកជន ក្រោមពាក្យស្លោក **“សុខភាពស្ត្រីល្អ កម្ពុជារឹងមាំ”** នេះជួយដល់ស្ត្រី និងគ្រួសារនៅក្នុងខេត្តចំនួនបួន គឺខេត្តកំពង់ចាម បាត់ដំបង សៀមរាប និងកំពត។ សម្រាប់ឆ្នាំ 2023 គម្រោងនេះនឹងរៀបចំវេទិកាអប់រំនៅតាមសហគមន៍ចំនួន 16ទីតាំង ដើម្បីបង្កើនការយល់ដឹង និងផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយដល់មនុស្សរាប់ពាន់នាក់បន្ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បន្ថែមពីប្រធានបទគោលរបស់ខ្លួន កិច្ចសហការនេះក៏ផ្តោតលើការកាត់បន្ថយអត្រាមរណភាពដោយសារជំងឺមហារីក បណ្តុះគំនិតទទួលយករបៀបរស់នៅដើម្បីទទួលបាន សុខភាពល្អ និងប្រយុទ្ធប្រឆាំង ជំងឺមិនឆ្លងដែលប៉ះពាល់ដល់សុខភាព និងជីវិត របស់មនុស្សទូទាំងពិភពលោក រួមទាំង កម្ពុជា ជាពិសេសស្ត្រី និងក្មេងស្រី។

ក្នុងវេទិកាអប់រំដែលប្រព្រឹត្តទៅក្នុងខេត្ត សៀមរាប ក៏មានវត្តមានចូលរួមយ៉ាងខ្ពង់ខ្ពស់របស់លោកជំទាវ សាន អារុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងវត្តមានសមាជិករបស់មន្ត្រីក្រសួងកិច្ចការនារី បានចូលរួមនៅទីតាំងទាំងបួន អ្នកតំណាងមកពីខេត្ត គណៈគ្រប់គ្រងមកពី AIA Cambodia បុគ្គលិក និងទីប្រឹក្សាផែនការជីវិត និងសាធារណជនទាំងឡាយ។ ស្ត្រីដែលបានចូលរួមក្នុងវេទិកាទាំងនោះ បានផ្តោតយកចិត្ត

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនស្ហួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

ទុកដាក់ព្យាយាមក្រេបជញ្ជក់យកចំណេះដឹងអំពី ជំងឺមហារីក និងការរៀបចំផែនអនាគត ហិរញ្ញវត្ថុរបស់គ្រួសារ ដើម្បីជួយកាត់បន្ថយភាពមិនប្រកដប្រជាផ្នែកហិរញ្ញវត្ថុ និងការខ្វាយខ្វល់អំពីអនាគត។

លោក Andrew Loh អគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុន AIA Cambodia បានមានប្រសាសន៍ថា៖ “យើងតែងតែយកចិត្តទុកដាក់លើស្រ្តីចាប់តាំងពីថ្ងៃដំបូងនៃ ដំណើរប្រតិបត្តិការនៅទីនេះក្នុងឆ្នាំ 2017 មកម្ល៉េះ។ គោលបំណងរបស់យើង គឺចង់ឱ្យពួកគាត់ឲ្យទទួលបានកាន់តែប្រសើរនូវ សុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងហិរញ្ញវត្ថុ តាមរយៈការអប់រំ និងការចែករំលែកព័ត៌មាននានា។ ភាពជាដៃគូរបស់យើងជាមួយ ក្រសួងកិច្ចការនារី មានគោលបំណងជួយដល់ស្រ្តី នៅគ្រប់មជ្ឈដ្ឋានទូទាំងប្រទេស ជាមួយការប្តេជ្ញាធ្វើវាឲ្យក្លាយជាការពិត។

លោកបានបន្ថែមថាក្នុងចំណោមគំនិតផ្តួចផ្តើមដើម្បីស្រ្តី របស់ AIA Cambodia រួមមានកម្មវិធីជជែកពិភាក្សា “ស្រ្តីធ្វើបាន” (The Best of Me) ដែលមានផ្សាយផ្ទាល់លើទំព័រ ហ្វេសប៊ុក បានផ្តល់ ការចែករំលែកដំបូន្មានពីវាគ្មិនកិត្តិយសល្បីដើម្បីជួយជ្រោមជ្រែង និងបំផុសគំនិតល្អៗសម្រាប់ស្រ្តី។ ទន្ទឹមនឹងនោះផងដែរក៏មានយុទ្ធនាការប្រចាំឆ្នាំ Fit for Hope ដែលបង្កើតឡើងដើម្បី លើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ដល់ស្រ្តី ដើម្បីស្វែងយល់អំពីជំងឺនេះ និងចេះបង្ការការការពារផងដែរ។

គម្រោងនេះផងដែរ បង្កើតឡើងស្របតាមគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដើម្បីជួយមនុស្សមួយពាន់លាននាក់នៅអាស៊ីឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរនៅឆ្នាំ 2030។ “សុខភាពស្រ្តីល្អ កម្ពុជារឹងមាំ” ជាគំនិតផ្តួចផ្តើមមួយរបស់គម្រោងគាំពារ និងគាំទ្រស្រ្តីរបស់ AIA Cambodia រួមមានកម្មវិធីជជែកពិភាក្សា “ស្រ្តីធ្វើបាន” ឬ The Best of Me ដើម្បីជួយលើកកម្ពស់ និងជម្រុញទឹកចិត្តស្រ្តី និងយុទ្ធនាការ ប្រចាំឆ្នាំ Fit For Hope ដើម្បីលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ ដើម្បីជួយស្រ្តីឲ្យយល់ដឹងច្បាស់អំពីជំងឺ និងវិធីការពារ។

“តាមរយៈសកម្មភាព និងគម្រោងរបស់យើង AIA Cambodia បន្តប្តេជ្ញា លើកកម្ពស់ស្រ្តីកម្ពុជា ផ្តល់ចំណេះដឹងដែលជាប្រយោជន៍ដល់ពួកគេ ផ្តល់លទ្ធភាពឱ្យពួកគាត់រួមចំណែកបន្ថែមទៀតដល់ប្រទេសជាតិ និងជួយពួកគាត់ឱ្យមានសុខភាព និងជីវិតកាន់តែប្រសើរ។”

ក្រសួង និង AIA Cambodia នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ រួមទាំងក្រសួងសុខាភិបាល និងអាជ្ញាធរ ដូចជាមន្ទីរកិច្ចការនារីថ្នាក់ខេត្ត-ក្រុង និង ស្រុក។

ដើម្បីស្វែងយល់បន្ថែមអំពីការលើកកម្ពស់សុខភាព និងសុខុមាលភាពហិរញ្ញវត្ថុរបស់ស្រ្តីកម្ពុជា ឬ ព័ត៌មានលម្អិតអំពី AIA Cambodia ផ្តល់ជូននូវដំណោះស្រាយលើជំងឺធ្ងន់ធ្ងរ និងគ្រោះថ្នាក់ចៃដន្យដើម្បី ការពារគ្រួសារអ្នក និងអ្នក សូមអ៊ីម៉ែលមកកាន់ kh.marketing@aia.com ។

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

## អំពី AIA Cambodia

ក្រុមហ៊ុនធានារ៉ាប់រង AIA Cambodia គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។

ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ AIA Cambodia ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា AIA Cambodia ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។

AIA Cambodia ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ  តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។

យើងខ្ញុំក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។

ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លឹបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។

AIA Cambodia គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់

 “ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)” ពី HR Asia ក្នុងរយៈពេល 3ឆ្នាំជាប់គ្នា 2020, 2021 និង 2022។

# អត្ថបទសារព័ត៌មាន

AIA Cambodia មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្ត សៀមរាប កំពត កំពង់ចាម និងបាត់ដំបង។

ព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.aia.com.kh


**ទំនាក់ទំនងសារព័ត៌មាន**
**ម៉េង ដាណែត**
**ប្រធានផ្នែកទំនាក់ទំនងសាធារណៈ**
**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
Daneth-d.Meng@aia.com